**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ៣២/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃដំណើរទស្សនកិច្ចការងាររបស់លោកជំទាវ Louise MUSHIKIWABO អគ្គលេខាធិការនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី នៅព្រះរាជាណាចក្រកម្ពុជា

តបតាមការអញ្ជើញរបស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា **លោកជំទាវ** Louise MUSHIKIWABO អគ្គលេខាធិការនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF) បានអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី១ ដល់ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៦ ក្នុងគោលបំណងជួយគាំទ្រប្រទេសកម្ពុជាក្នុងនាមជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០។ អំឡុងពេលទស្សនកិច្ច **លោកជំទាវអគ្គលេខាធិការ** ទទួលបានការចូលជួបសម្តែងការគួរសមជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបានជួបពិភាក្សាការងារទ្វេភាគីជាមួយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន**។

**លោកជំទាវអគ្គលេខាធិការ** និង **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានផ្លាស់ប្តូរយោបល់គ្នាពីវឌ្ឍនភាពនៃការត្រៀមរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ និង ១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ។ ថ្នាក់ដឹកនាំទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការលើកកម្ពស់តម្លៃនៃសន្តិភាព ការសន្ទនា និងសាមគ្គីភាពរបស់ហ្វ្រង់កូហ្វូនីនៅក្នុងបរិបទនៃការកើនឡើងអស្ថិរភាពភូមិសាស្ត្រនយោបាយ និងការរីករាលដាលនៃជម្លោះប្រដាប់អាវុធ។

ភាគីទាំងពីរបានបង្ហាញឆន្ទៈរួមគ្នាក្នុងការរៀបចំកិច្ចប្រជុំហ្វ្រង់កូហ្វូនីលើកទី២០ ឱ្យក្លាយជាព្រឹត្តិការណ៍ដ៏លេចធ្លោមួយ ក្រោយពីកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីត្រូវបានរៀបចំនៅតំបន់អាស៊ីប៉ាស៊ីហ្វិកកាលពី២៩ឆ្នាំកន្លងទៅ។ ថ្នាក់ដឹកនាំទាំងពីរសង្ឃឹមថា ប្រមុខរដ្ឋ/រដ្ឋាភិបាលជាច្រើននឹងអញ្ជើញចូលរួមកិច្ចប្រជុំនេះ ដែលជាឱកាសល្អផងដែរសម្រាប់ស្វែងយល់ពីសម្បត្តិវប្បធម៌ និងសក្តានុពលសេដ្ឋកិច្ចរបស់កម្ពុជា។

ក្នុងឱកាសទស្សនកិច្ចនៅកម្ពុជា **លោកជំទាវអគ្គលេខាធិការ** បានអញ្ជើញទៅទស្សនកិច្ចនៅខេត្តសៀមរាប ដើម្បីសួរសុខទុក្ខ**ជនភៀសសឹកចំនួន ៤១៤គ្រួសារ** ក្នុងជម្រកសុវត្ថិភាពបណ្តោះអាសន្នស្ថិតនៅបរិវេណ**វត្តធម្មរង្សី** ភូមិសំពៅលូន ស្រុកក្រឡាញ់ ។ **លោកជំទាវអគ្គលេខាធិការ** ក៏បានចុះទៅទស្សនា

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

សាលាទេសចរណ៍ Paul Dubrule ដែលទទួលជំនួយគាំទ្រពីអង្គការ OIF។ សាលានេះបានចូលរួមចំណែកបណ្តុះបណ្តាលផ្នែកសណ្ឋាគារ និងវិជ្ជាធ្វើម្ហូបដល់យុវជនកម្ពុជា ជាពិសេសការផ្តោតលើការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព។ ការវិនិយោគក្នុងវិស័យអភិវឌ្ឍន៍ជំនាញ និងការពង្រឹងសកម្មភាពយុវជន គឺជាអាទិភាពចម្បងរបស់អង្គការហ្វ្រង់កូហ្វូនី។

អំឡុងពេលស្នាក់នៅរាជធានីភ្នំពេញ **លោកជំទាវអគ្គលេខាធិការ** ក៏បានចុះពិនិត្យទីតាំងមួយចំនួនដែលត្រៀមសម្រាប់ទទួលរៀបចំ**កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ សន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៧** និងព្រឹត្តិការណ៍អមសំខាន់ៗ ដូចជា **«ភូមិហ្វ្រង់កូហ្វូនី»** និង**«ហ្វ្រង់កូតិច»** ជាដើម៕

ថ្ងៃសៅរ៍ ៤រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦